# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**********

**តុលាការកំពូល**

*****

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៦៩

ចុះថ្ងៃទី២៥ ខែវិច្ឆកា ឆ្នាំ១៩៩៩

**សាលដីកា**

លេខ: ១៣

ចុះថ្ងៃទី២៣ខែមេសាឆ្នាំ២០០៣

## គាទនាមប្រជារាស្ត្រខ្មែរ

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក ប៉ែន សារឿន ចៅក្រម

៥- លោក យស់ សូខឿន ចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

លោក សាន សុផាត

**តំណាងមហាអយ្យការ**

លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ២២២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៦៩ ចុះ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

**<u>ពីបទ:</u>** ឃាដកម្មគិតទុកជាមុន និងសមគំនិតសំលាប់មនុស្សគិតទុកជាមុន ប្រព្រឹត្តិនៅភូមិកោះចាស់ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១ និង៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-១៩៩២ ។

១-ជនជាប់ចោទឈ្មោះស៊ុន ស្រ៊ឹម (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកកោះធំ ខេត្តកណ្តាល របររកស៊ីអ្នកធាក់ស៊ីក្លូ ទីលំនៅមុនថ្ងៃផ្ទះលេខ៦២ ផ្លូវ១៧៤ ក្រុម៣៧ សង្កាត់ផ្សារថ្មីទី៣ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះអ៊ុំ ស៊ុន "រ" ម្តាយឈ្មោះប៉ែន ចេង "រ" ពោះម៉ាយ។ ក្នុងឃុំ ។

២-ជនជាប់ចោទឈ្មោះអ៊ុំ ម៉ាន់ (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកកោះធំ ខេត្តកណ្តាល របររកស៊ីអ្នកធាក់ស៊ីក្លូ ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះគ្មានលេខ ក្រុម៣៧ សង្កាត់

ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះតូច អ៊ុំ "ស" ម្តាយឈ្មោះយង់ ដៀង "ស" ប្រពន្ធឈ្មោះឡឹក នី មានកូន០៦នាក់ ។ ក្នុងឃុំ ។

៣-ជនជាប់ចោទឈ្មោះម៉ាន់ ធឿន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកកោះធំ ខេត្តកណ្តាល របររកស៊ីធ្វើស្រែ ទីលំនៅមុនថ្ងៃចាប់ខ្លួន ភូមិព្រែកតាម៉ែម ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ឪពុកឈ្មោះអ៊ឹ ម៉ាន់ "រ" ម្តាយឈ្មោះសៀន សែ ប្រពន្ធឈ្មោះស្រៀង ភាព មានកូន៤នាក់ ។ ក្នុងឃុំ ។

៤-ជនជាប់ចោទឈ្មោះម៉ាន់ ថុង (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើស្រែ កើតនិងទីលំនៅមុនថ្ងៃចាប់ខ្លួនភូមិព្រែកតាម៉ែម ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ឪពុកឈ្មោះម៉ាន់"ស" ម្តាយឈ្មោះយ៉ែម "ស" ប្រពន្ធឈ្មោះឆាម មានកូន៥នាក់ ។

-មានមេធាវី កញ្ញាស៊ាង បូរ៉ាវី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឃាន ឃន់ ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅ៧ក្នុងអង្គភាពអង្គរក្សសម្តេចជា ស៊ីម ។

-អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍(ជាម្ចាស់បណ្តឹងសាទុក្ខ)

-តាមពាក្យបណ្តឹងចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៨៧ របស់អ្នកទទួលសិទ្ធិឈ្មោះឃាន ឃន់ ប្តឹងពីឈ្មោះស៊ុន ស្រ៊ីម,អ៊ុំ ម៉ាន់,ម៉ាន់ ធឿន,ម៉ាន់ ថុង កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨៧ ជនល្មើសទាំង៤នេះ បានប្រើល្បិចកលបញ្ឆោតជនរងគ្រោះឈ្មោះសុះ សុផាត ឱ្យទៅលេងស្រុកកោះធំក្នុងបំណងសំលាប់ជនរងគ្រោះដើម្បីកេងប្រវ័ញ្ចយកទ្រព្យសម្បត្តិ ។ ពេលផឹកស៊ីជនល្មើសទាំង៤ បានបង្អកស្រាឱ្យជនរងគ្រោះស្រវឹងរួចនាំជនរងគ្រោះទៅសំលាប់ចោលក្នុងទឹកទន្លេ ។ ជនរងគ្រោះបន្សល់ទុកកូន០៣នាក់ ហេតុនេះសូមឱ្យផ្តន្ទាទោសជនល្មើសនិងទាជំងឺចិត្តចំនួន២០តម្លឹងមាស ពីជនល្មើសទាំង៤នាក់នេះ សុំដកយកម៉ូតូធុនតូចជារបស់ជនល្មើសព្រមទាំងសម្ភារៈក្នុងផ្ទះដែលរក្សាទុកនៅប្រពន្ធជនល្មើសឈ្មោះអ៊ុំ ម៉ាន់ ដើម្បីយកមកផ្គត់ផ្គង់ជីវភាពកូនរបស់សពទាំង៣នាក់ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកណ្តាល ថា : ចោទប្រកាន់លើឈ្មោះស៊ុន ស្រ៊ីម,អ៊ុំ ម៉ាន់,ម៉ាន់ ធឿន,ម៉ាន់ ថុង ឃុំខ្លួនពីបទ: ឃាដកម្មគិតទុកជាមុន និងសមគំនិតសំលាប់មនុស្ស ប្រព្រឹត្តនៅភូមិកោះចាស់ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល តាមមាត្រា៣១ និង៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៨"ក" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៨៧ របស់តុលាការខេត្តកណ្តាល ដែលបានសំរេច :

១-ផ្តន្ទាទោស:

ក-ឈ្មោះស៊ុន ស្រ៊ីម ដាក់ពន្ធនាគារកំណត់១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៨-០២-៨៧ ។

ខ-ឈ្មោះអ៊ុំ ម៉ាន់ ដាក់ពន្ធនាគារកំណត់១៨ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៨-០២-៩៧ ។

គ-ឈ្មោះម៉ាន់ ធឿន ដាក់ពន្ធនាគារកំណត់១៣ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៧-០២-៩៧ ។

ឃ-ឈ្មោះម៉ាន់ ថុង ដាក់ពន្ធនាគារកំណត់១៣ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៧-០២-៩៧ ។

ពីបទ: ឃាដកម្មគិតទុកជាមុន និងសមគំនិតសំលាប់មនុស្សគិតទុកជាមុនប្រព្រឹត្តនៅភូមិកោះចាស់ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៧ ។ បទល្មើសព្រហ្មទណ្ឌដែល មានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា៣១ និង៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-អោយឈ្មោះស៊ុន ស្រ៊ឹម ឈ្មោះអ៊ុំ ម៉ាន់,ឈ្មោះម៉ាន់ ធឿន និងម៉ាន់ ថុង រួមគ្នាសងសំណងជំងឺចិត្តទៅអោយឈ្មោះឃាន ឃាន់ ជាតំណាងជនរងគ្រោះជាប្រាក់ចំនួន៥.០០០.០០០(ប្រាំលានរៀល)សំណងលើសពីនេះត្រូវលើកចោល ។

ករណីគ្មានប្រាក់សងគ្រប់ចំនួនទេ ត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ ។

៣-វត្ថុតាងមានៈ ដែកក្លៀវទេះចំនួន០១ប្រវែង៦៥cm ត្រូវរឹបអូសរួចបំផ្លាញចោល ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទកំបាំងមុខតំណាងជនរងគ្រោះឈ្មោះឃាន ឃន់។ តំណាងជនរងគ្រោះឈ្មោះឃាន ឃន់ មានសិទ្ធិប្តឹងជំទាស់កំណត់១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ និងមានសិទ្ធិប្តឹងឧទ្ធរណ៍កំណត់២ខែ ។ជនជាប់ចោទមានសិទ្ធិប្តឹងឧទ្ធរណ៍កំណត់២ខែ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់ឈ្មោះស៊ុន ស្រ៊ឹម,អ៊ុំ ម៉ាន់, ម៉ាន់ ធឿន និង ម៉ាន់ ថុង ប្តឹងមិនសុខចិត្តលើសាលក្រមលេខ២៨ "ក" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់ តុលាការកណ្តាល លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា:

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៧ របស់ជនជាប់ចោទឈ្មោះស៊ុន ស្រ៊ឹម ,អ៊ុំ ម៉ាន់ ,ម៉ាន់ ធឿន និងម៉ាន់ ថុង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៨ "ក" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្តាលទុកជាបានការ តែគួរកែប្រែចំណុចដូចបានចង្អុលបង្ហាញខាងលើ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២២២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៣៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៧ របស់ឈ្មោះស៊ុន ស្រ៊ឹម,អ៊ុំម៉ាន់ ម៉ាន់ ធឿន និងម៉ាន់ ថុង ជាជនជាប់ចោទទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៨"ក" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៧ របស់តុលាការខេត្ត កណ្ដាលទុកជាបានការពេញទាំងមូល តែបដិសេធបទចោទប្រកាន់ និងការផ្ដន្ទាទោសជនជាប់ចោទពីបទសម គំនិតក្នុងអំពើឃាដកម្មគិតទុកជាមុនចោលជាអសារបង់ ចំណុចផ្សេងទៀតនៃសាលក្រមរក្សាទុកដដែល ។

៣-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារឱ្យជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ តែចាតទុកជាចំពោះមុខ បើផ្លូវប្ដឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ៩០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់អគ្គឯកឧត្ដមអគ្គព្រះរាជ អាជ្ញា អមសាលាឧទ្ធរណ៍ ប្ដឹងមិនសុខចិត្តលើសាលដីកាព្រហ្មទណ្ឌលេខ២២២ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃបទសមគំនិត ។

- បានឃើញសារណាបណ្ដឹងសាទុក្ខចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ របស់អគ្គព្រះរាជអាជ្ញា អមសាលា ឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណា ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០១ របស់អ្នកស្រីឃុន គឹមលន់ មេធាវីការពារក្ដី ឱ្យឈ្មោះស៊ុន ស្រ៊ឹម,អ៊ុំ ម៉ាន់ ម៉ាន់ ធឿន និងម៉ាន់ ថុង (ជាចុងបណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា: សូមតម្កល់សាលដីកា សាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្ដាប់ចម្លើយអះអាងរបស់ឈ្មោះម៉ាន់ ថុង (ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះ ថា: ខ្ញុំមិន បានដឹងទេ ឪពុកខ្ញុំបាទនាំជនរងគ្រោះពីភ្នំពេញមកផឹកស៊ីនៅផ្ទះម្ដាយមីងក្បែរផ្ទះខ្ញុំ ក្រោយពីផឹកស៊ីប្រហែល ម៉ោង៧-៨ក៏នាំជនរងគ្រោះទៅសួរសុខទុក្ខបងប្អូនឈើនៅឯត្រើយម្ខាង លុះដល់កណ្ដាលទន្លេឈ្មោះស៊ុន ស្រ៊ឹម សំលាប់ជនរងគ្រោះតែម្ដង ។

ក្នុងរឿងនេះខ្ញុំពុំបានដឹងអ្វីទេ រឿងសំលាប់គ្រោងទុកមុន ខ្ញុំក៏មិនដឹងដែរគេហៅឡើងទូកក៏ឡើងតាម គេ ។ សូមតុលាការលើកលែងចោទប្រកាន់ ។

-បានស្ដាប់ចម្លើយអះអាងរបស់ឈ្មោះម៉ាន់ ធឿន (ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះ ថា: ខ្ញុំមិនបានចូលរួមផឹកស៊ីជាមួយពួកគេ ក្រោយពីខ្ញុំតាមហៅបងខ្លួននៅឯចំការមកខ្ញុំមិនបានទៅណាទេ គេហៅខ្ញុំ ជិះទូកជាមួយ ខ្ញុំមិនបានដឹងគេរៀបគំរោងធ្វើស្អី ស្រាប់តែមានរឿងសំលាប់ជនរងគ្រោះតែម្ដង។ សូមតុលាការ មេត្តាដោះលែងខ្ញុំបាទ ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់កញ្ញាសាង បូរ៉ាវី មេធាវីការពារជនជាប់ចោទឈ្មោះស៊ុន ស្រ៊ឹម អ៊ុំ ម៉ាន់ (ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ក្នុងរឿងនេះ ពុំមានភស្ដុតាងដាក់បន្ទុកលើកូន ក្ដីខ្ញុំឈ្មោះម៉ាន់ ថុង,ម៉ាន់ ធឿន អ្នកទាំង២មិនបានដឹងថាឪពុកខ្ញុំធ្វើបែបនេះឡើយ ណាមួយបែកឪពុក២-៣ឆ្នាំ

ទៀត រឿងសំលាប់ជនរងគ្រោះកូនក្តីខ្លួនក៏មិនដឹងទេ និងជនជាប់ចោទឈ្មោះអ៊ី ម៉ាន់ និងស៊ិន ស្រ៊ឹម សូមតុលាការបន្ធូបន្ថយទោសផង ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: សូមតម្កល់ការសន្និដ្ឋានទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចំលើយជនជាប់ចោទឈ្មោះម៉ាន់ ថុង និងម៉ាន់ ធឿន សារណារបស់ជនជាប់ចោទឈ្មោះស៊ិន ស្រ៊ឹម និងឈ្មោះអ៊ី ម៉ាន់ ព្រមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៩០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៨នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបដិសេធបទចោទប្រកាន់ និងការផ្តន្ទាទោសពីបទសមគំនិតធ្វើមនុស្សឃាដគិតទុកជាមុន" មិនអាចនាំឱ្យជនជាប់ចោទ៣នាក់ ឈ្មោះអ៊ី ម៉ាន់,ម៉ាន់ ថុង និងម៉ាន់ ធឿន រួចខ្លួនបានទេ ពីព្រោះថាតាមដីកាសន្និដ្ឋានស្ថាពរ និងតាមសាលក្រមរបស់តុលាការខេត្តកណ្តាលបានសំរេចចោទប្រកាន់ និងផ្តន្ទាទោសជនជាប់ចោទទាំង៤នាក់ជារួមថា: ពីបទ "មនុស្សឃាដគិតទុកជាមុននិងសមគំនិតធ្វើមនុស្សឃាដគិតទុកជាមុន" ។ ប៉ុន្តែសាលាឧទ្ធរណ៍ដែលសំរេចលប់ "បទសមគំនិតធ្វើមនុស្សឃាដគិតទុកជាមុន" ដោយសាលាឧទ្ធរណ៍យល់ឃើញរួចហើយ នៅក្នុងសាលដីការបស់ខ្លួនថា ជនជាប់ចោទទាំង៤នាក់នេះគឺជាសហចារីក្នុងបទមនុស្សឃាដដោយគិតទុកជាមុនមានន័យថាមិនមានជនជាប់ចោទណាមួយជាអ្នកសមគំនិតទេ ។ ដូច្នេះការដែលសាលាឧទ្ធរណ៍សំរេចបដិសេធបទ"សមគំនិតក្នុងអំពើមនុស្សឃាដដោយគិតទុកជាមុន" នេះគឺមានន័យគ្រប់គ្រាន់ថា ផ្តន្ទាទោសជនជាប់ចោទទាំង៤នាក់ ពីបទមនុស្សឃាដដោយគិតទុកជាមុនហើយ។ សាលាឧទ្ធរណ៍មានសមត្ថកិច្ចកែប្រែបទល្មើសបានតាមមាត្រា១៦៣ និង១៦៤នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា នៅពេលសវនាការនេះ មេធាវីជនជាប់ចោទបានសំណូមពរឱ្យតុលាការកំពូល ពិចារណា និងសំរេចឱ្យជនជាប់ចោទឈ្មោះម៉ាន់ ថុង និងម៉ាន់ ធឿន រួចខ្លួន ហើយបន្ធូបន្ថយទោសដល់ជនជាប់ចោទឈ្មោះស្រ៊ិន ស៊ីម និង អ៊ី ម៉ាន់ តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាបានទេ ពីព្រោះជនជាប់ចោទ

ចោទពុំបានប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ឡើយ ហើយបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាប្តឹងតែមួយចំណុចដែលទាក់ទងតែនឹងទំរង់នៃសាលដីកាប៉ុណ្ណោះ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយាន យន់ ពុំបានមកចូលរួមសវនាការនេះទេ តុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះស៊ុន ស្រ៊ីម និងអ៊ុំ ម៉ាន់ ពុំបានមកចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវីបានមកចូលរួមហើយ ដូច្នេះតុលការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២២២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ ម៉ាន់ មឿន និងម៉ាន់ មុង**
**កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះស៊ុន ស្រ៊ីម**
**និងអ៊ុំ ម៉ាន់ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។**

១- ទទួលបណ្តឹងសាទុក្ខលេខ៩០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២២២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ។